# របាយការណ៍ប្រចាំត្រីមាសទី១
# ឆ្នាំ ២០២៤

០១ មករា - ៣១ មីនា ២០២៤

## អ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (០) ២៣-៨៨៨-០០០, ទូរស័ព្ទចល័ត: +៨៥៥ (០) ២៣-៤២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៩១៥.៤៩២.៧០៣ | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ |
| បំណុលសរុប | ៤១៣.៥៣៦.៣៨០ | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ |
| មូលធនក្រុមហ៊ុនសរុប | ៥០១.៩៥៦.៣២៣ | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី ១ ឆ្នាំ២០២៤ | ត្រីមាសទី ១ ឆ្នាំ២០២៣ | ត្រីមាសទី ១ ឆ្នាំ២០២២ |
|---|---|---|---|
| ចំណូលសរុប | ៤៣២.១១៥.៤០៣ | ៦៣១.១៨៨.៣០៦ | ៤២៩.៦៦៨.៩១៧ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២៦.១២៤.០០៦ | ៨៨.៧១៣.៥០៩ | ៥៤.៣៨២.៧៤៣ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ២០.៨៧៣.០៧៦ | ៦៩.៦៥៥.៩២៣ | ៤៨.០៧១.៣៧២ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ១៥.៤០៩.៣៥៩ | ៦២.៥៣៧.៨០៧ | ៤៦.២៣៣.២១១ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី ១ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| អនុបាតសាធនភាព | ០,៨ | ១,២ | ១,០ |
| អនុបាតចរន្ត (Current Ratio) | ៣,៥ | ២,៥ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ១,១ | ០,៦ | ០,៧ |

| អនុបាតចំណេញភាព | ត្រីមាសទី ១ ឆ្នាំ២០២៤ | ត្រីមាសទី ១ ឆ្នាំ២០២៣ | ត្រីមាសទី ១ ឆ្នាំ២០២២ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១,៥% | ៦,៨% | ៨,២% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៣,១% | ១៣,៥% | ១៥,០% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៤,៣% | ១៨,៣% | ១៧,៦% |
| គម្លាតចំណេញ (Profit Margin) | ៣,៦% | ៩,៩% | ១០,៨% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៤,២ | ១៧,៣ | ២៨,២ |

## ក្រាបស្ដីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
700,000,000
600,000,000
500,000,000
400,000,000
300,000,000
200,000,000
100,000,000
-
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
៤២៩.៦៦៨.៩១៧
៦៣១.១៨៨.៣០៦
៤៣២.១១៥.៤០៣
១០,៨%
៩,៩%
៣,៦%
ត្រីមាសទី១ ឆ្នាំ២០២២
ត្រីមាសទី១ ឆ្នាំ២០២៣
ត្រីមាសទី១ ឆ្នាំ២០២៤
ប្រាក់ចំណូល
ចំណូលសុទ្ធ %

## សមាជិកក្រុមប្រឹក្សាភិបាល



លោក Christian Wiedmann | លោក ខន សាំខ | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

**លោក Kevin Whitcraft**

ប្រធានក្រុមប្រឹក្សាភិបាល

**លោក ខន សាំខ**

អភិបាលប្រតិបត្តិ

**លោក Tom Whitcraft**

អភិបាលមិនប្រតិបត្តិ

**លោក Christian Wiedmann**

អភិបាលមិនប្រតិបត្តិ

**លោក Ith Vichit**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ការវិភាគអន្តរជាតិជាច្រើនបានពន្យាករថា កំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជានឹងកើនឡើងដល់ចំនួន ៥,៨% នៅក្នុងឆ្នាំ២០២៤ ដោយការប៉ាន់ប្រមាណនៅក្នុងឆ្នាំ២០២៣ មានចំនួន ៥,២%។ ចក្ខុវិស័យនៃស្ថេរភាពសេដ្ឋកិច្ចត្រូវបានបង្ហាញឱ្យឃើញនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ តាមរយៈការនាំចេញរបស់កម្ពុជាដែលមានការកើនឡើងចំនួន ១៨% ដែលបានកើនឡើងដល់ ៦,៣ ប៊ីលានដុល្លារ បើធៀបទៅនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន ។ ការវិនិយោគផ្ទាល់ពីបរទេសក៏បានពង្រឹងផងដែរ តាមរយៈទឹកប្រាក់ជាង ២,២ ប៊ីលានដុល្លារ វិនិយោគចូលក្នុងប្រទេស ក្នុងរយៈពេលបីខែដំបូងនៃឆ្នាំ២០២៤។ កំណើននេះអាចត្រូវបានជម្រុញដោយផ្នែកទៅលើការកើនឡើងនៅក្នុងវិស័យទេសចរណ៍ដែលមានភ្ញៀវទេសចរជាង១លាននាក់បានមកទស្សនានៅប្រទេសកម្ពុជានៅក្នុងអំឡុងត្រីមាសទី១។

តាមគន្លងកំណើននេះ យើងប៉ាន់ស្មានថា ទីផ្សាររថយន្តនៅកម្ពុជាក្នុងត្រីមាសទី១នេះ បានកើនឡើងចំនួន ៤២% ដែលគួរឱ្យចាប់អារម្មណ៍ បើធៀបត្រីមាសចុះក្រោយនៃឆ្នាំ២០២៣។ RMAC បានឆ្លុះបញ្ចាំពីលទ្ធផលនេះ ដែលមានការកើនឡើង ៤០%ប្រចាំត្រីមាស។ ទោះជាយ៉ាងណាក៏ដោយការលក់របស់ RMAC បានធ្លាក់ចុះ ៣២% បើធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំមុន ដោយយើងទទួលស្គាល់ថាការលក់នៅត្រីមាសទី១ នៃឆ្នាំ២០២៣ គឺជាការលក់ប្រចាំត្រីមាសដែលខ្ពស់បំផុតនៅប្រទេសកម្ពុជា។

នៅក្នុងអំឡុងត្រីមាសនេះ RMAC បានបន្តការខិតខំប្រឹងប្រែងរបស់ខ្លួនជាមួយនឹងការដាក់បង្ហាញនូវរថយន្ត ម៉ាក FUSO 1.5T FE71 ស៊េរីថ្មីទាំងអស់ ដែលជាប្រភេទរថយន្តដឹកទំនិញ ប្រើប្រាស់បានយូរ និងសាកសមសម្រាប់ទីផ្សារកម្ពុជា។ នៅខែមីនា យើងបានធ្វើការបង្ហាញនូវបច្ចេកវិទ្យាជឿនលឿនចុងក្រោយបំផុតដល់អតិថិជន Land Rover របស់យើងនូវរថយន្ត Rang Rover SV PHEV ស៊េរីថ្មី ដែលបានតាំងបង្ហាញនៅក្នុងបន្ទប់តាំងបង្ហាញរថយន្តរបស់យើង ។ ស្របតាមការប្តេជ្ញាចិត្តរបស់ RMAC ក្នុងការបង្កើននូវបទពិសោធន៍ចំពោះអតិថិជនរបស់ RMAC យើងខ្ញុំពិតជាមានមោទនភាពក្នុងការប្រកាសនូវការវិនិយោគសំខាន់ៗចំនួនពីរនៅក្នុងត្រីមាសទី១នេះ ក្នុងគោលបំណង ធ្វើទំនើបកម្មគ្រឿងបរិក្ខាររបស់យើង។ ការវិនិយោគទីមួយ គឺទាក់ទងទៅនឹងការកែលម្អ និងពង្រីកទីស្នាក់ការសេវាកម្មថែទាំក្រោយការលក់សម្រាប់រថយន្តម៉ាក Range Rover ដ៏ប្រណិតរបស់យើង។ ការវិនិយោគគម្រោងទី២ គឺបើកដំណើរការទីស្នាក់ការត្រួតពិនិត្យមុនពេលចែកចាយនិងដឹកជញ្ជូនរថយន្ត (PDI) លំដាប់ពិភពលោកនៅបឹងបៃតង រាជធានីភ្នំពេញ ដែលនឹងនាំឱ្យការបម្រើដល់អតិថិជនកាន់តែប្រសើរឡើងមួយកំរិតទៀត។

ខាងផ្នែកទំនួលខុសត្រូវសង្គម RMAC ពិតជាមានសេចក្តីសោមនស្សរីករាយដែលបានបរិច្ចាគកៅអីចំនួន ៣០ កៅអី ដល់រដ្ឋបាលខេត្តកំពត ដើម្បីលើកកម្ពស់និងបង្កើនសុខុមាលភាពដល់សហគមន៍មូលដ្ឋាន។

ខ្ញុំបាទតំណាងឱ្យក្រុមប្រឹក្សាភិបាលទាំងអស់ សូមថ្លែងអំណរគុណចំពោះអតិថិជនដែលមានភក្តីភាពនឹងអតិថិជនដែលមានចំណង់ចំណូលចិត្តខ្ពស់ទាំងអស់នៅក្នុងប្រទេសកម្ពុជាដែលតែងតែគាំទ្រដល់យើងកន្លងមក។ យើងក៏សូមជូនពរឱ្យប្រជាជនកម្ពុជាទាំងអស់មានសុខសុវត្ថិភាព និងសុខភាពល្អ។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

## មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... 3
ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ..... 5
សមាជិកក្រុមប្រឹក្សាភិបាល ..... 7
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល..... 8
ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ..... 11
ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ..... 11
ខ .សកម្មភាពអាជីវកម្ម..... 11
គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយ:ពេលនៃរបាយការណ៍ត្រីមាស ..... 12
ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... 14
ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក..... 14
ខ .រចនាសម្ព័ន្ធប្រាក់ចំណូល..... 15
ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ..... 16
ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណ:គ្រប់គ្រង ..... 17
ក .ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ..... 17
ខ .កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ..... 18
គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល..... 18
ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ..... 18
ង. ផលប៉ះពាល់នៃអតិផរណា..... 18
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ..... 18
ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ..... 18
ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ..... 19

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៩៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៩២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, TCM, JCB, FUSO, John Deere, Jaguar Land Rover, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, AJAX, Piaggio, Changan, Haulotte, សេវាកម្មក្រោយការលក់ Mercedes-Benz និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និងអាគុយ) ដែលបានបន្ថែមនៅក្នុងឆ្នាំ២០២៣។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ខែមករា ឆ្នាំ២០២៤

**សកម្មភាពខាងក្រៅរបស់បុគ្គលិក អរ អិម អេ (ខេមបូឌា)** ( RMAC OFFSITE )

ក្រុមការងារ និង ការចូលរួមយ៉ាងសកម្មរបស់បុគ្គលិកនៅសកម្មភាពខាងក្រៅ និងភាពសប្បាយរីករាយ!



### ខែកុម្ភៈ ឆ្នាំ២០២៤

**ការពង្រីកសេវាកម្មក្រោយការលក់របស់** LAND ROVER

Land Rover AFS ត្រូវបានកែលម្អ និងពង្រីកជាមួយនឹងច្រកលើកចំនួន ៤ បន្ថែមទៀត ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តឥតងាករេរបស់ RMAC ចំពោះឧត្តមភាព និងសេវាកម្មដល់អតិថិជន។



**ការសម្ពោធរថយន្តស៊េរីថ្មីម៉ាក** FUSO 1.5T FE71

សេចក្តីណែនាំអំពីទីផ្សារប្រទេសកម្ពុជា រថយន្តដឹកទំនិញ FUSO ស៊េរីថ្មីដែលល្បីល្បាញដោយសារភាពធន់ និងការដំណើរការរបស់វា។



### ខែមីនា ឆ្នាំ២០២៤

**LOGO ថ្មី**

ការរចនាឡើងវិញនៃនិមិត្តសញ្ញាពិភពលោក របស់យើងឥឡូវនេះ គ្របដណ្តប់គ្រប់តំបន់ទាំងអស់នៅ (អាស៊ី ME អឺរ៉ុប និងអាហ្វ្រិក) ដែលជានិមិត្តរូបតំណាងអោយវត្តមានសកល និងការប្តេជ្ញាចិត្តរបស់គ្រុបយើង ក្នុងការបម្រើសហគមន៍ចម្រុះនៅទូទាំងពិភពលោក។



## **សូមណែនាំរថយន្តថ្មីម៉ាក** RANGE ROVER SV PHEV



ព្រឹត្តិការណ៍នេះ បានធ្វើឡើងនៅគេហដ្ឋានប្រណីត «Norea Cove»។ ការសម្តែងនេះបានបង្ហាញពីភាពប្រណិត និងការច្នៃប្រឌិតរបស់ Land Rover ។

## **ការត្រួតពិនិត្យមុនពេលចែកចាយរបស់** FORD (PDI) **និងការបើកដំណើរការទីស្នាក់ការដឹកជញ្ជូន**



ក្រុមហ៊ុន Ford សាខាបឹងបៃតងបានរៀបចំពិធីសម្ពោធជាផ្លូវការនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២៥។ រោងចក្រនេះមានទំហំ ៦,៥០០ ម៉ែត្រការ៉េ ហើយនឹងផ្តល់សេវាកម្ម PDI លំដាប់ពិភពលោក និងសេវាកម្មដឹកជញ្ជូនដល់អតិថិជន Ford របស់យើង។

## **ការបើកសម្ពោធរថយន្តស៊េរីថ្មី** FORD RANGER




ព្រឹត្តិការណ៍នេះ ត្រូវបានរៀបចំឡើងនៅ ដឹ ព្រេមៀ សេនធ័រ សែនសុខ នៅចំពោះមុខភ្ញៀវដែលបានអញ្ជើញចំនួន ២,០០០ នាក់ និងវត្តមានរបស់លោក David Jeffrey (ជានាយកប្រតិបត្តិទីផ្សារអ្នកចែកចាយរបស់Ford AP)។

## **ពានរង្វាន់សម្រាប់ការច្នៃប្រឌិតឌីជីថលនៃ** JCB GLOBAL




ផ្នែក បរិក្ខារធុនធ្ងន់ (HED) កម្ពុជា បានទទួលពានរង្វាន់ កានច្នៃប្រឌិតឌីជីថល ក្នុងការទទួលស្គាល់សម្រាប់ការខិតខំប្រឹងប្រែងឥតឈប់ឈរ ដើម្បីទទួលយកការផ្លាស់ប្តូរឌីជីថល និងការប្រើប្រាស់ឧបករណ៍ឌីជីថល។

## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

នៅត្រីមាសទី១ ឆ្នាំ២០២៤ បានបង្ហាញសញ្ញាគួរឱ្យការកត់សម្គាល់ពីការស្ទុះងើបឡើងវិញ នៃវិស័យយានយន្ត នៅប្រទេសកម្ពុជា ដោយមានការកើនឡើងចំនួន +៤២% បើប្រៀបធៀបទៅនឹងត្រីមាសចុងក្រោយនៃឆ្នាំ២០២៣។ ទោះយ៉ាងណាក៏ដោយ ទីផ្សារនៅតែធ្លាក់ចុះ-២៨% បើធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំ២០២៣។

ក្នុងកំឡុងត្រីមាសនេះ RMAC បានរីកចម្រើនសៀងគ្នា ខណៈដែលទីផ្សារទាំងមូលកំពុងកើនឡើង+៣៨% ធៀបនឹងត្រីមាសចុងក្រោយនៃឆ្នាំ២០២៣។ នៅក្នុងផ្នែកសំខាន់ៗរបស់យើង៖

<u>**ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖**</u>

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយ ដែលលក់ដាច់បំផុតនៅលើទីផ្សារក្នុងប្រទេសកម្ពុជា។ យើងពិតជាមានមោទនភាពដែលយានយន្តដែលលក់បានភាគច្រើនត្រូវបានផលិតក្នុងប្រទេសកម្ពុជា។

<u>**គ្រឿងចក្រម៉ាក John Deere៖**</u> ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន រថយន្តម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា ហើយបានដណ្តើមយកចំណាត់ថ្នាក់ទីផ្សារវិញក្នុងកំឡុងឆ្នាំ ២០២៣។

<u>**លទ្ធផលហិរញ្ញវត្ថុ៖**</u>

អរគុណចំពោះទីផ្សាររបស់រថយន្តដែលកំពុងស្ទុះងើបឡើងវិញ និងទស្សនវិស័យវិជ្ជមានលើវិស័យកសិកម្ម។ ក្រុមហ៊ុន RMAC ទទួលបានប្រាក់ចំណូលចំនួន ៨៣២,១ ប៊ីលានរៀល ដែលមានការកើនឡើង +៣៨% ក្នុងដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ បើធៀបនឹងត្រីមាសមុន គឺត្រីមាសទី៤ ឆ្នាំ២០២៣ (ចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៣) ដែលមានការធ្លាក់ចុះ-៣២% បើប្រៀបធៀបទៅនឹងប្រាក់ចំណូលនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ។ សម្រាប់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ២០,៩ ប៊ីលានរៀល (-ធ្លាក់ចុះ -៧០% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៣)។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ០,៦ ប៊ីលានរៀល ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី១ ឆ្នាំ២០២៤ និងរយៈពេលប្រៀបធៀបកាលពីឆ្នាំមុន។

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ២០២៤ | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៤១១.៨៥៨.២៧៤ | ៩៥,៣% | ៦១៥.០៣៩.៣៣២ | ៩៧,៤% | ៤១៤.៥៨៣.២៣៤ | ៩៦,៥% |
| **ចំណូលនៃសេវាកម្ម** | ២០.២៥៧.១២៩ | ៤,៧% | ១៦.១៤៨.៩៧៤ | ២,៦% | ១៥.០៨៥.៦៨៣ | ៣,៥% |
| **សរុប** | ៤៣២.១១៥.៤០៣ | ១០០,០% | ៦៣១.១៨៨.៣០៦ | ១០០,០% | ៤២៩.៦៦៨.៩១៧ | ១០០,០% |

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៤៣២,១ ប៊ីលានរៀល ធ្លាក់ចុះចំនួន -៣៥៥,៣ ប៊ីលានរៀល ឬ -៣១,៥% ភាគរយ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ បើធៀបនឹងត្រីមាសដូចគ្នាក្នុង ឆ្នាំ២០២៣។

#### ២. ផ្នែកនៃចំណូល

ផ្នែករថយន្ត ហ្វត (Ford) គ្រឿងចក្រធុនធ្ងន់ (Heavy-Equipment) និង ផ្នែក ម៉ូតូកង់បី (Piaggio) ត្រូវទទួលបានកំណត់ត្រាអវិជ្ជមានយ៉ាងខ្លាំងនៃការធ្លាក់ចុះចំណូលនៅក្នុងត្រីមាស១ ឆ្នាំ២០២៤ បើធៀបទៅនឹងឆ្នាំមុន ខណៈពេលដែលរថយន្តម៉ាក Land Rover, Changan គ្រឿងចក្រកសិកម្ម (Agriculture) និងផលិតផលពិសេសរបស់ RMA ទទួលការកើនឡើងកំណត់ត្រាខ្លាំងជាងឆ្នាំមុន។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ២០២៤ | ត្រីមាសទី១ ឆ្នាំ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៤៣២.១១៥.៤០៣ | ៦៣១.១៨៨.៣០៦ | (១៩៩.០៧២.៩០៣) | -៣១,៥% |
| ចំណេញដុល | ៦១.៨៤៨.០៧៧ | ១១៥.៦២៩.៤០៦ | (៥៣.៧៨១.៣២៩) | -៤៦,៥% |
| គម្លាតចំណេញដុល | ១៤,៣% | ១៨,៣% | | |
| ចំណាយ | ២៧.៥៣២.២១៨ | ២១.៤៧៥.០៩៨ | ៦.០៥៧.១២០ | ២៨,២% |
| ចំណាយហិរញ្ញវត្ថុ | ៨.១៩១.៨៥៣ | ៥.៤៤០.៧៩៩ | ២.៧៥១.០៥៤ | ៥០,៦% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៦.១២៤.០០៦ | ៨៨.៧១៣.៥០៩ | (៦២.៥៨៩.៥០៣) | -៧០,៦% |
| គម្លាត | ៦,០% | ១៤,១% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ២០២៤ | ត្រីមាសទី១ ឆ្នាំ ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៦.១២៤.០០៦ | ៨៨.៧១៣.៥០៩ | (៦២.៥៨៩.៥០៣) | -៧០,៦% |
| ចំណាយពន្ធ | ៥.២៥០.៩៣០ | ១៩.០៥៧.៥៨៦ | (១៣.៨០៦.៦៥៦) | -៧២,៤% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ២០.៨៧៣.០៧៦ | ៦៩.៦៥៥.៩២៣ | (៤៨.៧៨២.៨៤៧) | -៧០,០% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៤,៨% | ១១,០% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងស្តុកទុកនូវធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៤ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២៣ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាពេលថ្មីៗនេះ យើងមិនត្រូវទទួលបានការជូនដំណឹងអំពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ឬ រូបិយវត្ថុដែលអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ RMAC តាមរបៀបណាមួយឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ១៥ ឧសភា ២០២៤

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

